# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១០ . អនក្រ . បក**

0487
02 02

ច្បាប់ចម្លង
នាយកដ្ឋាន.រដ្ឋបាល.

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយមន្ទីរពេទ្យកុមារជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

៙ ✵ ៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១២៩៧ /៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

មន្ទីរពេទ្យកុមារជាតិ សរសេរកាត់ថា **ម.ព.ក.ជ.** ត្រូវបានសម្រេចឱ្យប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសុខាភិបាល និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២.-**

**ម.ព.ក.ជ.** ជានីតិបុគ្គល និងមានស្វ័យភាពហិរញ្ញវត្ថុ។

**ម.ព.ក.ជ.** មានអាសយដ្ឋានជីឡូត៍លេខ១០០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ **ម.ព.ក.ជ.**។

**មាត្រា៣.-**

**ម.ព.ក.ជ.** មានភារកិច្ចជាអាទិ៍ដូចតទៅ៖

- រ៉ាប់រងការពិគ្រោះ ផ្តល់សេវាសុខាភិបាលផ្នែកព្យាបាលថែរក្សាជំងឺកុមារ ការធ្វើរោគវិនិច្ឆ័យ សល្យសាស្ត្រផ្នែកកុមារគ្រប់ប្រភេទដែលបានបញ្ជូនមក ឬបានសុំមកសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ហើយផ្តល់សេវាជូនការស្នាក់នៅតាមលទ្ធភាពរបស់មន្ទីរពេទ្យ
- ផ្តល់ការថែរក្សាព្យាបាលជំងឺស្រាល ឬជំងឺធ្ងន់ទៅតាមឯកទេស
- ផ្តល់ជូនអ្នកជំងឺគ្រប់រូបនូវការពិនិត្យព្យាបាល តាមតម្រូវការ និងលទ្ធភាពរបស់សាមីអង្គភាព
- ពិគ្រោះយោបល់ និងព្យាបាលជំងឺដោយមិនមានការរើសអើង និងតាមកម្រិតបច្ចេកទេសដូចគ្នា ប៉ុន្តែអាចផ្តល់របបស្នាក់នៅកម្រិតខុសគ្នា អាស្រ័យតាមឆន្ទៈរបស់អ្នកជំងឺ ឬគ្រួសារអ្នកជំងឺ ឬ អាស្រ័យតាមលទ្ធភាពថវិការបស់អ្នកជំងឺ ដោយអនុលោមតាមតម្លៃសេវាកម្មរបស់មន្ទីរពេទ្យ
- ធ្វើសហការក្នុងផ្នែកវេជ្ជសាស្ត្រ បង្ការការពារ និងផ្តល់សេវាសម្រាប់វេជ្ជសេវាកិច្ចអាសន្ន
- ចាត់វិធានការដើម្បីឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ឬរ៉ាប់រងសម្រួលឱ្យអ្នកជំងឺទៅព្យាបាលនៅមន្ទីរពេទ្យដទៃទៀត
- ផ្តល់ឱ្យអ្នកជំងឺនូវការព្យាបាលរោគ ការបង្ការរោគ និងការសម្រាលរោគតាមស្តង់ដារវេជ្ជសាស្ត្រ
- ចាត់ចែងឱ្យបានល្អត្រឹមត្រូវនូវការព្យាបាលបន្ទាន់លើគ្រប់ផ្នែកនិងអាស្រ័យតាមមធ្យោបាយរបស់មន្ទីរពេទ្យ

- ចូលរួមបណ្តុះបណ្តាលនិងស្រាវជ្រាវវិស័យវេជ្ជសាស្ត្រ ទន្តសាស្ត្រ ឱសថសាស្ត្រព្រមទាំងជួយបណ្តុះបណ្តាលបុគ្គលិក
- ធ្វើសហការក្នុងផ្នែកព្យាបាល បង្ការការពារ និងអប់រំសុខភាពកុមារ
- ធ្វើសហប្រតិបត្តិការនានាក្រោមការណែនាំពីក្រសួងសុខាភិបាល ។

## ជំពូកទី២

## ការដឹកនាំនិងការគ្រប់គ្រង

### ផ្នែកទី១

### ក្រុមប្រឹក្សាភិបាលរបស់ ម.ព.ក.ជ.

**មាត្រា៤._**

**ម.ព.ក.ជ.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិទូលំទូលាយ ដើម្បីចាត់ចែងការងារក្នុងក្របខណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ **ម.ព.ក.ជ.** ។

**មាត្រា៥._**

**៥.១.** ក្រុមប្រឹក្សាភិបាលមានសមាជិក ៧ (ប្រាំពីរ) រូប ដែលមានសមាសភាពដូចតទៅះ

- តំណាងក្រសួងសុខាភិបាល — ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- ឥស្សរជនដែលមានចំណេះដឹង និងបទពិសោធខាងវិទ្យាសាស្ត្រសុខាភិបាល — សមាជិក
- តំណាងសាលារាជធានីភ្នំពេញ — សមាជិក
- នាយកនៃ **ម.ព.ក.ជ.** — សមាជិកស្វ័យប្រវត្តិ
- តំណាងបុគ្គលិកនៃ **ម.ព.ក.ជ.** — សមាជិកស្វ័យប្រវត្តិ

**៥.២.** តំណាងបុគ្គលិកនៃ **ម.ព.ក.ជ.** ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក **ម.ព.ក.ជ.** សម្រាប់អាណត្តិនីមួយៗ ។

**៥.៣.** ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលដែលមិនមែនជាសមាជិកស្វ័យប្រវត្តិត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ (បី) ឆ្នាំ និងអាចបន្តបានទៀត តាមសំណើរបស់ក្រសួង ឬស្ថាប័នដែលសមាជិកនោះជាតំណាង ។

**៥.៤.** អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលាដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬស្ថាប័នដែលសមាជិកនោះជាតំណាង ។

**មាត្រា៦._**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានបទពិសោធគ្រប់គ្រាន់ មានជំនាញខ្ពស់ក្នុងវិស័យសុខាភិបាល សេដ្ឋកិច្ច ឬនីតិសាស្ត្រ

ដែលមានសញ្ជាតិខ្មែរ និងមានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលបានទទួលទណ្ឌកម្មពីបទមជ្ឈិម ឬបទឧក្រិដ្ឋពីតុលាការឡើយ ។

**មាត្រា៧.-**

**៧.១.** ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

**៧.២.** ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធលើវិស័យវិទ្យាសាស្ត្រសុខាភិបាល និងតំណាងដៃគូអភិវឌ្ឍឱ្យចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលបាន ។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

**មាត្រា៨.-**

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តម្រង់ទិស និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ **ម.ព.ក.ជ.** ។ ក្នុងក្របខណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

- ពិនិត្យ និងសម្រេចលើគម្រោងផែនការអភិវឌ្ឍនៃ **ម.ព.ក.ជ.** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និងសម្រេចលើគម្រោងផែនការសកម្មភាពនៃ **ម.ព.ក.ជ.**
- ពិនិត្យ និងសម្រេចលើចំណូល និងចំណាយប្រចាំឆ្នាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ម.ព.ក.ជ.**
- ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងការបែងចែកភារកិច្ចជាទូទៅដល់គ្រប់ការិយាល័យ និងអង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍតាមការចាំបាច់របស់ **ម.ព.ក.ជ.**
- កំណត់បែបបទនៃការជ្រើសរើស ការដំឡើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក **ម.ព.ក.ជ.** ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះមន្ត្រីមុខងារសាធារណៈ
- សម្រេចលើក្របខណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសម្រាប់ **ម.ព.ក.ជ.**
- សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្មសាធារណៈ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ
- កែសម្រួលបទបញ្ជាផ្ទៃក្នុងនៃ **ម.ព.ក.ជ.** ដោយមានការយល់ព្រមពីប្រធានស្ថាប័ន ឬក្រសួងអាណាព្យាបាលទាំងពីរ
- វាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ **ម.ព.ក.ជ.** ហើយកំណត់វិធានការកែតម្រូវដើម្បីអនុវត្ត ។

**មាត្រា៩.-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

មាត្រា១០._

**១០.១.** ក្រុមប្រឹក្សាភិបាលនៃ **ម.ព.ភ.ជ.** ត្រូវធ្វើការប្រជុំយ៉ាងតិច ៣ (បី)ខែម្តង តាមគំនិតផ្តួចផ្តើម និងការអញ្ជើញរបស់ប្រធាន ឬ តាមការស្នើរបស់សមាជិកចំនួន ២/៣ (ពីរភាគបី) ឡើងទៅ ឬតាមការស្នើសុំរបស់នាយកនៃ **ម.ព.ភ.ជ.**។ ក្នុងករណីមានធុរៈ ប្រធានត្រូវផ្ទេរសិទ្ធិជូនសមាជិកណាម្នាក់ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំ ត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ១ (មួយ)រូបដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ។

របៀបវារៈព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច១០(ដប់) ថ្ងៃ មុនថ្ងៃប្រជុំ។

**១០.២.** ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានចំនួនសមាជិកលើសពី ៥០ (ហាសិប)ភាគរយនៃចំនួនសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានកូរ៉ុមគ្រប់ចំនួនឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញប្រជុំលើកមុន។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំចាត់ទុកជាឧត្តមានុភាព។

**១០.៣.** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ការរបស់ **ម.ព.ភ.ជ.** និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះត្រូវបង្ហាញអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ។

**១០.៤. ម.ព.ភ.ជ.** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ៖

- កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់ **ម.ព.ភ.ជ.**
- គម្រោងថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។

**១០.៥.** ឯកសារទាំងនេះត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនហួសពី ១៥ (ដប់ប្រាំ) ថ្ងៃ

## ផ្នែកទី២

## អង្គការប្រតិបត្តិរបស់ ម.ព.ក.ជ.

**មាត្រា១១.-**

**ម.ព.ក.ជ.** ត្រូវគ្រប់គ្រងដោយនាយកមន្ទីរពេទ្យមួយរូបដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកមន្ទីរពេទ្យរូបនេះមានតួនាទីជានាយកប្រតិបត្តិ។

**មាត្រា១២.-**

**១២.១.** នាយកនៃ **ម.ព.ក.ជ.** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។

នាយកនៃ **ម.ព.ក.ជ.** មានភារកិច្ចៈ

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាលនេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ម.ព.ក.ជ.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យគណនីហិរញ្ញវត្ថុប្រចាំឆ្នាំនិងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ម.ព.ក.ជ.** ក្នុងការកម្រិតក្របខណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ **ម.ព.ក.ជ.** ដែលក្រុមប្រឹក្សាភិបាលកំណត់តាមការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត។

**១២.២.** នាយកនៃ **ម.ព.ក.ជ.** ជាតំណាងរបស់មន្ទីរពេទ្យ ក្នុងការទាក់ទងជាមួយតតិយជន។

**១២.៣.** នាយកនៃ **ម.ព.ក.ជ.** ត្រូវស្នើទៅក្រសួងសុខាភិបាលសុំតែងតាំងនាយករង មួយរូប ឬច្រើនរូបជាជំនួយការ តាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។ នាយកនិងនាយករងត្រូវមានចំណេះដឹងលើផ្នែកគ្រប់គ្រង។

## ផ្នែកទី៣

## បុគ្គលិករបស់ ម.ព.ក.ជ.

**មាត្រា១៣.-**

**១៣.១.** បុគ្គលិកអចិន្ត្រៃយ៍របស់ **ម.ព.ក.ជ.** មានមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈមកពីក្រសួងសុខាភិបាល ឬមកពីក្រសួងស្ថាប័នរដ្ឋដទៃទៀត។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកក្របខណ្ឌ ប្រាក់បៀវត្សនិងប្រាក់កម្រៃផ្សេងៗ ដែលកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

**១៣.២. ម.ព.ក.ជ.** អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្ដែត។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្ដីពីការងារ។

**១៣.៣.** បុគ្គលិក **ម.ព.ក.ជ.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្ដីពីការគ្រប់គ្រងបុគ្គលិកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ចំពោះមន្ត្រីរាជការនៃមុខងារសាធារណៈ បទបញ្ជានេះមិនត្រូវផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់ប្រាក់កម្រៃ លើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ផងដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

## ផ្នែកទី៤

## ទ្រព្យសម្បត្តិរបស់ ម.ព.ក.ជ.

**មាត្រា១៤.-**

**១៤.១. ម.ព.ក.ជ.** ទទួលជាដើមទុនដំបូងពីរដ្ឋនូវដីធ្លី និងអចលនវត្ថុដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធតាមបញ្ជីសារពើភណ្ឌចុងក្រោយ ដែលផ្ទៃដីមាន ៤២ ៨២៨ (សែសិបពីរពាន់ ប្រាំបីរយម្ភៃប្រាំបី) ម៉ែត្រក្រឡាស្ថិតនៅដីឡូត៍លេខ១០០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**១៤.២. ម.ព.ក.ជ.** អាចទិញ ប្ដូរ ឬលក់ចលនទ្រព្យ អចលនទ្រព្យចាំបាច់សម្រាប់ដំណើរការមន្ទីរពេទ្យបាន ដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន។

## ផ្នែកទី៥

## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ម.ព.ក.ជ.

**មាត្រា១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ **ម.ព.ក.ជ.** ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ។

**មាត្រា១៦.-**

**១៦.១.** នាយករបស់ **ម.ព.ក.ជ.** ជាអាណាប័កដើមខ្សែរបស់មន្ទីរពេទ្យហើយត្រូវមានភារកិច្ចៈ

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ។

**១៦.២.** អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវវជ្ជទេយ្យចំណាយថ្មី[illegible]បាន ដោយមានការព្រមព្រៀងពីគណនេយ្យករ **ម.ព.ក.ជ.** ។

**មាត្រា១៧.-**

**១៧.១.** ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ **ម.ព.ក.ជ.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ គណនេយ្យករនេះត្រូវទទួលខុសត្រូវចំពោះមុខនាយក **ម.ព.ក.ជ.** និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់តែឥតមានសំឡេងឆ្នោតឡើយ។

**១៧.២.** គណនេយ្យករមានភារកិច្ចៈ

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- ថែរក្សា និងចាត់ចែងប្រើប្រាស់មូលនិធិ និងធនធានរបស់ **ម.ព.ក.ជ.**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ។

**១៧.៣.** គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុករីរបស់ខ្លួន។

**មាត្រា១៨.-**

**១៨.១.** ប្រភពធនធានរបស់ **ម.ព.ក.ជ.** រួមមានៈ

- ធនធានដំបូងរបស់រដ្ឋផ្ដល់ដល់ **ម.ព.ក.ជ.** នៅពេលផ្ដើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធនដែលមានចែងក្នុងថវិកាជាតិ
- អំណោយ ជំនួយ និងអច្ច័យទានដែល **ម.ព.ក.ជ.** បានទទួល
- ប្រាក់ខ្ចីដោយផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ **ម.ព.ក.ជ.**
- ផលការងារ និងកម្រៃនៃការផ្ដល់សេវាផ្សេងៗដោយ **ម.ព.ក.ជ.**
- កម្រៃនៃទ្រព្យរបស់ **ម.ព.ក.ជ.** និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលត្រូវបានទទួលអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលត្រូវបានប្រគល់ឱ្យ **ម.ព.ក.ជ.**។

**១៨.២.** ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ **ម.ព.ក.ជ.** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់មន្ទីរពេទ្យ។ ក្រុមប្រឹក្សាភិបាលរបស់ **ម.ព.ក.ជ.** ត្រូវកំណត់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា។ សេចក្ដីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងនឹងទម្រង់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកាត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៨.៣. ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ **ម.ព.ក.ជ.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និងចំណាយ។

១៨.៤. អនុលោមតាមមាត្រា ១៣ ខាងលើនេះ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ នៃមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈដែលមកបម្រើការងារក្នុង **ម.ព.ក.ជ.** ជាបន្ទុកនៃថវិការដ្ឋ។

១៨.៥. ប្រាក់ឧបត្ថម្ភរបស់រដ្ឋដែលបានគ្រោងទុកក្នុងថវិកាជាតិ ដើម្បីផ្តល់ឱ្យ **ម.ព.ក.ជ.** ត្រូវសំដៅជាពិសេសលើចំណាយថ្លៃទឹក និងថ្លៃភ្លើង។

១៨.៦. សោហ៊ុយវិភាគ និងសោហ៊ុយដំណើរការ សម្រាប់ស្រាវជ្រាវវិភាគ សម្រាប់ពេលមានអាសន្ន ត្រូវចែងក្នុងកិច្ចសន្យាមួយរវាងរដ្ឋ និង **ម.ព.ក.ជ.** ដែលមានបញ្ជាក់ចំណែកដែលភាគីម្ខាងៗត្រូវរ៉ាប់រង។

**មាត្រា១៩.-**

១៩.១. ការងារគណនេយ្យរបស់ **ម.ព.ក.ជ.** រួមមាន៖

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគដែលចែងអំពីប្រតិបត្តិការថវិការតនាគារនិងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យអសង្ហារិម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់។

គណនេយ្យរបស់ **ម.ព.ក.ជ.** ត្រូវ៖

- ស្របតាមវិធានការដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យរបស់ **ម.ព.ក.ជ.** ដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះត្រូវបានយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៩.២. របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ម.ព.ក.ជ.** ត្រូវរៀបចំដោយគណនេយ្យករនិងអាណាប័កដើមខ្សែដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

**មាត្រា២០.-**

មូលនិធិរបស់ **ម.ព.ក.ជ.**គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅអគ្គនាយកដ្ឋានរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៦

## របបសារពើពន្ធរបស់ ម.ព.ក.ជ.

**មាត្រា២១.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលមានចែងដោយច្បាប់ **ម.ព.ក.ជ.** ត្រូវស្ថិតនៅក្រោមនីតិវិធីធម្មតានៃរបបសារពើពន្ធ។

## ផ្នែកទី៧

## លទ្ធកម្មរបស់ ម.ព.ក.ជ.

**មាត្រា២២.-**

ការសម្រេច ការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ **ម.ព.ក.ជ.** ត្រូវគ្រប់គ្រងតាមច្បាប់ និងបទបញ្ញាទាំងឡាយជាធរមាន ដែលពាក់ព័ន្ធនឹងកិច្ចការនេះ ។

# ជំពូកទី៣

# អាណាព្យាបាលភាព

## ផ្នែកទី១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា២៣.-**

**២៣.១.** ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពេលប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ម.ព.ក.ជ.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃទទួលឯកសារដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានរយៈពេល ២(ពីរ) ខែ ចាប់ពីថ្ងៃទទួលឯកសារ ដែលបានបញ្ជូនដោយនាយកនៃ **ម.ព.ក.ជ.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

**២៣.២.** លិខិតយល់ព្រមចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាងត្រូវផ្ញើជូនទៅនាយកនៃ **ម.ព.ក.ជ.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយកនៃ **ម.ព.ក.ជ.** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាទទួលបានការឯកភាព ។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងសុខាភិបាល ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍនៃ **ម.ព.ក.ជ.** និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា២៤.-**

**២៤.១.** រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចមានយោបល់ជំទាស់លើឯកសារដែលត្រូវបានបញ្ជូនដូចមានចែងក្នុងមាត្រា ១០ ចំណុច ១០.៤ នៃអនុក្រឹត្យនេះ មានកំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល របាយការណ៍ស្តីពីការ

គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ១(មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ។

**២៤.២.** នាយកនៃ **ម.ព.ក.ជ.** ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលអំពីខ្លឹមសារនៃការជំទាស់របស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់នេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនេះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជាបន្ទាន់ភ្លាមនូវដំណឹងអំពីបញ្ហានេះជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា២៥.–**

**២៥.១.** រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចលុប ឬផ្អាកទុកនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ម.ព.ក.ជ.** ក្នុងករណីដែលសេចក្តីសម្រេចនោះ៖

- ផ្ទុយនឹងគោលដៅរបស់មន្ទីរពេទ្យ
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ធ្វើឡើងដោយអាជ្ញាធរមួយដែលពុំមានសិទ្ធិសម្រេច ឬធ្វើឡើងដោយការប្រជុំពុំស្របច្បាប់ របស់ក្រុមប្រឹក្សាភិបាល។

**២៥.២.** ការលុបចោល ឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយកនៃ **ម.ព.ក.ជ.** ហើយនាយកនៃ **ម.ព.ក.ជ.** ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា២៦.–**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងាររបស់ **ម.ព.ក.ជ.** ក្នុងករណីយល់ថា ជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា២៧.–**

**២៧.១.** ក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ម.ព.ក.ជ.** ត្រូវផ្ញើរបាយការណ៍ស្តីពីការគ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល១ (មួយ)ខែចាប់ពីថ្ងៃទទួលឯកសារដើម្បីផ្តល់យោបល់

ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរយៈពេល ២ (ពីរ) ខែ ចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយនាយកនៃ **ម.ព.ក.ជ.** ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៧.២.** លិខិតយល់ព្រមចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាងត្រូវផ្ញើជូនទៅនាយកនៃ **ម.ព.ក.ជ.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកនៃ **ម.ព.ក.ជ.** ត្រូវបញ្ជូនព័ត៌មាននេះ ទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនបានឆ្លើយតប ក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ។ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

**មាត្រា២៨.–**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ម.ព.ក.ជ.** ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន៖

- សេចក្តីសម្រេចស្តីពីការលើកលែងតណទេយ្យដែលមានទឹកប្រាក់លើសពីការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ
- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនទ្រព្យ។

សេចក្តីសម្រេចនេះ ត្រូវអនុលោមតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៩.–**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ១ (មួយ) រូប ប្រចាំ **ម.ព.ក.ជ.**។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើ **ម.ព.ក.ជ.** ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

**មាត្រា៣០.–**

**៣០.១.** ការគ្រប់គ្រងដោយអាណាប័កដើមខ្សែនៃ **ម.ព.ក.ជ.** ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៣០.២.** ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់[illegible]នៃអគ្គនាយកដ្ឋានរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣០.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើ **ម.ព.ភ.ជ.** នៅពេលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ